ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីបំភ្លឺ
# ស្តីពី
# ការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ណាហ្គាវើលដ៍

ការិយាល័យអ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមធ្វើការបំភ្លឺជូនសាធារណជនឱ្យបានជ្រាបអំពីសាវតារនៃវិវាទការងាររួម និងការដោះស្រាយករណីវិវាទការងាររួមនៅក្រុមហ៊ុន ណាហ្គាវើលដ៍ ដូចខាងក្រោម ៖

## ១. សាវតារនៃវិវាទ

ការរីករាលដាលនៃជំងឺកូវីដ-១៩ បានធ្វើឱ្យវិស័យទេសចរណ៍ សេវាកម្សាន្ត និងបដិសណ្ឋារកិច្ចនៅទូទាំងពិភពលោក ក៏ដូចជានៅប្រទេសកម្ពុជា ជួបផលលំបាកយ៉ាងធ្ងន់ធ្ងរ។ វិបត្តិជំងឺកូវីដ-១៩ បានធ្វើឱ្យមានការបន្តធ្លាក់ចុះភ្ញៀវទេសចរណ៍ ការរៀបចំសកម្មភាពអាជីវកម្មឡើងវិញ និងការកែសម្រួលរចនាសម្ព័ន្ធផ្ទៃក្នុងឱ្យស្របតាមការរក្សាគម្លាតសង្គម និងវិធានការសុខាភិបាលផ្សេងទៀត។ ដោយមូលហេតុនេះ នៅខែមេសា ឆ្នាំ២០២១ ក្រុមហ៊ុន ណាហ្គាវើលដ៍ បានជូនដំណឹងដល់សហជីព និងប្រជុំជាមួយតំណាងកម្មករនិយោជិតអំពីគម្រោងកាត់បន្ថយបុគ្គលិកក្នុង ១២ផ្នែក ដែលមានចំនួន ១ ៣២៩នាក់ ដោយមានហេតុផលសមរម្យ និងស្របតាមនីតិវិធីនៃច្បាប់ផងដែរ។ ទន្ទឹមនឹងនេះ ក៏មានបុគ្គលិកចំនួន ២៩២នាក់ផ្សេងទៀត បានស្ម័គ្រចិត្តមកសុំលាឈប់ពីការងារដោយខ្លួនឯង ដែលធ្វើឱ្យចំនួនបុគ្គលិក ដែលត្រូវកាត់បន្ថយបានកើនដល់ចំនួន ១ ៦២១នាក់ ដែលក្នុងនោះមានបុគ្គលិកចំនួន ៣៧៣នាក់ មិនយល់ព្រមលើការបញ្ឈប់ពីការងាររួមនេះ។

បន្ទាប់ពីទទួលបានពាក្យបណ្តឹង អ្នកផ្សះផ្សាវិវាទនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចេញលិខិតបញ្ជាក់អ្នកតំណាងបុគ្គលិក ក្នុងការដោះស្រាយវិវាទការងាររួម ដែលមានសមាសភាពដូចការស្នើសុំចំនួន ៩នាក់ ដែលដឹកនាំដោយលោកស្រី **ឈឹម ស៊ីថរ** រួចបានធ្វើការផ្សះផ្សាលើបណ្តឹងទាមទារទាំង ៥ចំណុចរបស់តំណាងបុគ្គលិក ដោយទទួលបានលទ្ធផលសះជាចំនួន ១ចំណុច និងមិនសះជាចំនួន ៤ចំណុច ដែលត្រូវបានបញ្ជូនសំណុំរឿងទៅដោះស្រាយបន្តនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។

បន្ទាប់ពីភាគីទាំងពីរបានជ្រើសរើសអាជ្ញាកណ្តាលដោយខ្លួនឯង និងសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច អាជ្ញាកណ្តាលបានបើកសវនាការចំនួន ២លើក ទៅតាមនីតិវិធីជាធរមាន ហើយបានចេញសេចក្តីបង្គាប់លេខ ០១២/២២ ណាហ្គាវើលដ៍ លីមីធីត ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១ ដោយបដិសេធពិចារណាចំណុចទី១ (ទាមទារឱ្យក្រុមហ៊ុនបញ្ឈប់គម្រោងកាត់បន្ថយបុគ្គលិក), និងចំណុចទី២ (ការបញ្ឈប់ការបំភិតបំភ័យបុគ្គលិកតាមរយៈការហៅទៅជួបអ្នកគ្រប់គ្រងក្រុមហ៊ុន), ហើយបានបង្គាប់ឱ្យអនុវត្តចំណុចទី៣ (ការផ្តល់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារតាមច្បាប់សម្រាប់អ្នកដែលយល់ព្រមឈប់) និងចំណុចទី៤ (ការបន្តផ្តល់ឡើងវិញនូវប្រាក់បំណាច់អតីតភាពការងារឆ្នាំ២០២០ និងឆ្នាំ២០២១ ជូនបុគ្គលិកក្នុងឆ្នាំ២០២១ និងគណនាឱ្យបាន

ត្រឹមត្រូវតាមច្បាប់)។ ប៉ុន្តែភាគីសហជីពបានប្ដឹងជំទាស់នឹងសេចក្ដីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលមកក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដែលធ្វើឱ្យសេចក្ដីបង្គាប់នេះមិនអាចអនុវត្តបាន។

បន្ទាប់មក នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ ក្រសួងទទួលបានលិខិតរបស់សហជីព ស្នើឱ្យក្រុមហ៊ុនទទួលយកអតីតបុគ្គលិកចំនួន ៣៧៣នាក់ ចូលបម្រើការងារវិញ ដែលក្រសួងបានណែនាំឱ្យសហជីពគួរអនុវត្តទៅតាមនីតិវិធីនៃការដោះស្រាយវិវាទការងារដែលច្បាប់កំណត់ ដោយប្ដឹងបន្តទៅតុលាការនូវកម្មវត្ថុនៃបណ្ដឹងដែលត្រូវបានដោះស្រាយរួចហើយដោយក្រុមប្រឹក្សាអាជ្ញាកណ្ដាល និងដាក់ពាក្យបណ្ដឹងសាជាថ្មីមកក្រសួងចំពោះកម្មវត្ថុទាមទារណាដែលមិនទាន់ត្រូវបានឆ្លងកាត់ការដោះស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល។

នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ សហជីពបានដាក់លិខិតមួយផ្សេងទៀតមកក្រសួង ដោយទាមទារ ៣ចំណុចថ្មី បន្ថែមទៀត។ ប៉ុន្តែ ដោយមិនទាន់បានឆ្លងកាត់នីតិវិធីដោះស្រាយនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាលផងសហជីពបានសម្រេចចិត្តរំលងចោលដំណាក់កាលនេះ និងដំណាក់កាលនៃការប្ដឹងបន្តទៅតុលាការ ហើយបែរជាយកការធ្វើកូដកម្មដើម្បីដោះស្រាយវិវាទការងារនេះ ដោយបានជូនដំណឹងទៅនិយោជក និងចម្លងជូនក្រសួងពីការសម្រេចចិត្តធ្វើកូដកម្មនៅមុខក្រុមហ៊ុនចាប់ពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២១ ដើម្បីទាមទាររហូតដល់ចំនួន ៩ចំណុច ដែលខុសពីបញ្ញត្តិនៃច្បាប់ស្ដីពីការងារ ដែលបានកំណត់ថាមានតែចំណុចដែលត្រូវបានដោះស្រាយនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាលប៉ុណ្ណោះ ទើបអាចក្លាយទៅជាកម្មវត្ថុនៃការធ្វើកូដកម្ម។

ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ សាលាដំបូងរាជធានីភ្នំពេញបានចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដោយបានសម្រេចហាមឃាត់ និងបានកំណត់គុណវុឌ្ឍិកូដកម្មនោះថាជាកូដកម្មខុសច្បាប់។ តុលាការបានបញ្ជាក់ថា វិវាទការងាររួមនៅក្រុមហ៊ុន ណាហ្គាវើលដ៍នេះ ជាវិវាទដែលពាក់ព័ន្ធវិធានទាក់ទងនឹងដំណោះស្រាយរបស់អាជ្ញាកណ្ដាល និងជាវិវាទដែលមានចំណុចទាមទារថ្មី ហើយមិនទាន់ត្រូវបានដោះស្រាយដោយអាជ្ញាកណ្ដាលដែលជាកម្មវត្ថុនៃការទាមទារដែលមិនអនុញ្ញាតឱ្យភាគីកម្មករនិយោជិតប្រើប្រាស់សិទ្ធិធ្វើកូដកម្ម ដូចមានចែងក្នុងច្បាប់ស្ដីពីការងារឡើយ។

បន្ទាប់មកទៀត ដោយមានការប្រព្រឹត្តសកម្មភាពផ្សេងៗខុសនឹងច្បាប់ មានអតីតបុគ្គលិកមួយចំនួនត្រូវបានចោទពីបទព្រហ្មទណ្ឌចំពោះសកម្មភាពល្មើសរបស់ខ្លួន ហើយអតីតបុគ្គលិកទាំងនោះបានធ្វើលិខិតមកក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ស្នើសុំជួយផ្ដល់កិច្ចអន្តរាគមន៍តាមផ្លូវច្បាប់ឱ្យពួកគាត់បាននៅក្រៅឃុំជាបណ្ដោះអាសន្ន ដើម្បីបានចូលរួមស្វែងរកដំណោះស្រាយ និងឈានទៅបញ្ចប់វិវាទការងារនេះ ដោយបានសន្យាថានឹងសហការជាមួយអាជ្ញាធរក្នុងការអនុវត្តឱ្យបានម៉ឺងម៉ាត់នូវវិធានការសុខាភិបាល មិនរារាំងការយកសំណាក មិនធ្វើការប្រមូលផ្ដុំ ឬដឹកនាំតវ៉ាណាមួយដែលធ្វើឱ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គមជាតិនោះឡើយ។ ក្នុងនាមជាអាណាព្យាបាល ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈបានធ្វើលិខិតទៅក្រសួងយុត្តិធម៌ ហើយក្រសួងយុត្តិធម៌ក៏បានធ្វើលិខិតទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីផ្ដល់កិច្ចអន្តរាគមន៍តាមផ្លូវច្បាប់ឱ្យអតីតបុគ្គលិកទាំងនោះនៅក្រៅឃុំបណ្ដោះអាសន្ន ដោយមានមេធាវីរបស់ក្រសួងជាអ្នកធានាលើអ្នកដែលត្រូវចោទទាំងនោះ។ សាលាដំបូងរាជធានីភ្នំពេញ បានចេញដីកាសម្រេចអនុញ្ញាតឱ្យអតីតបុគ្គលិកទាំងនោះនៅក្រៅឃុំជាបណ្ដោះអាសន្ន កាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២។

## ២. ដំណោះស្រាយរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ តាមរយៈយន្តការគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា បានកោះអញ្ជើញភាគីទាំងពីរមកចរចាទល់មុខគ្នាបាន ១៨លើក (បន្ទាប់ពីតំណាងអតីតបុគ្គលិកបាននៅក្រៅឃុំជាបណ្ដោះអាសន្ន) និងជួបចរចាដោយឡែកជាច្រើនលើកផងដែរ ដើម្បីស្វែងរកលទ្ធភាពជម្រើសដំណោះស្រាយ។ ប៉ុន្តែ វិវាទនេះមិនបានសះជាឡើយ ដោយចំណុចដែលមិនសះជា

និងគ្មានដំណោះស្រាយនោះ គឺភាគីអតីតបុគ្គលិកនៅតែបន្តទាមទារឱ្យក្រុមហ៊ុនត្រូវតែទទួលយកអតីតបុគ្គលិកដែលនៅសេសសល់ឱ្យចូលធ្វើការវិញ ចំណែកក្រុមហ៊ុនបានបន្តបដិសេធលើការទាមទារនេះ ដោយយល់ព្រមអនុវត្តការទូទាត់សំណងស្របតាមច្បាប់ជាធរមានជំនួសវិញ។ តាមច្បាប់ ក្រសួងមិនអាចបង្ខំឱ្យភាគីណាមួយត្រូវតែយល់ព្រមតាមអ្នកផ្សះផ្សាវិវាទឡើយ។ ការព្រម ឬមិនព្រមទទួលយកអតីតបុគ្គលិកឱ្យចូលធ្វើការវិញគឺអាស្រ័យទៅលើការសម្រេចចិត្តរបស់ភាគីនិយោជកស្របតាមនីតិវិធីច្បាប់។

គិតត្រឹមថ្ងៃទី១ ខែតុលា ឆ្នាំ២០២២ នេះ មានអតីតបុគ្គលិកសរុបចំនួន ២៤៤នាក់ ក្នុងចំណោម ៣៧៣នាក់ បានយល់ព្រមទទួលយកការទូទាត់នូវប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារជាមួយក្រុមហ៊ុន ដែលធ្វើឱ្យចំនួនអតីតបុគ្គលិកដែលមិនព្រមទទួលយកសំណងនៅសល់ត្រឹមតែចំនួន ១២៩នាក់ ប៉ុណ្ណោះ។ ចំពោះអតីតបុគ្គលិកដែលនៅសេសសល់ ក្រសួងនឹងរៀបចំកិច្ចប្រជុំនៅថ្ងៃទី៦ ខែតុលា ឆ្នាំ២០២២ ដើម្បីបន្តសម្របសម្រួលដោះស្រាយវិវាទការងារនេះ។

ចំពោះបញ្ហាដែលជាប់គាំងកន្លងមកនេះ គឺមិនមែនជាការព្រងើយកន្តើយរបស់ក្រសួងឡើយ។ ជាក់ស្តែង ក្រសួងបានខិតខំធ្វើការសម្របសម្រួល ស្របតាមតួនាទីដែលកំណត់ដោយច្បាប់ ក៏ដូចជាការទាមទាររបស់គូភាគី។ ការជាប់គាំងគឺដោយសារតែគូភាគីវិវាទមិនមានឆន្ទៈក្នុងការអនុវត្តនីតិវិធីដោះស្រាយវិវាទការងាររួមឱ្យបានត្រឹមត្រូវដែលតាមជាក់ស្តែង គឺត្រូវប្តឹងបន្តទៅតុលាការ។ ផ្ទុយទៅវិញ ភាគីអតីតបុគ្គលិកបែរជាជ្រើសរើសធ្វើការតវ៉ាខុសច្បាប់ក្នុងអំឡុងពេលដែលកំពុងដោះស្រាយទៅវិញ។ ទោះជាយ៉ាងណាក៏ដោយ ក្រសួងនឹងបន្តរៀបចំកិច្ចប្រជុំ និងសម្របសម្រួលករណីវិវាទនេះជាបន្តទៀត ហើយក្នុងករណីដែលភាគីវិវាទទាំងពីរនៅតែមិនអាចរកដំណោះស្រាយ និងសម្របសម្រួលគ្នាបាននោះ ក្រសួងសូមលើកទឹកចិត្តឱ្យភាគីទាំងពីរយកករណីវិវាទនេះប្តឹងទៅតុលាការដើម្បីជម្រះសេចក្តី ស្របតាមបទប្បញ្ញត្តិនៃការដោះស្រាយវិវាទការងាររួមជាធរមាន។

សម្រាប់បងប្អូនអតីតបុគ្គលិក ដែលមិនទាន់មានការងារថ្មី ហើយមានបំណងស្វែងរកការងារធ្វើ សូមទាក់ទងមកទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានអាសយដ្ឋានស្ថិតនៅមហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឬទំនាក់ទំនងតាមរយៈទូរសព្ទលេខ 077 232 378 / 016 786 655 ឬតាមរយៈគេហទំព័រ www.nea.gov.kh និងហ្វេសប៊ុក www.facebook.com/neakhmer ដើម្បីក្រសួងស្វែងរកការងារថ្មីជូនដូចអតីតបុគ្គលិកមួយចំនួនបានធ្វើកន្លងមកនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជ្រាបតាមការគួរ។

ថ្ងៃសៅរ៍ ៦កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១ ខែតុលា ឆ្នាំ២០២២